# ១ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


២៩-១១-២០០០ -ព្រះរាជក្រម នស/រកម/១១០០/១១ ច្បាប់ ស្តីពីច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ១៨២៧


### ២-ព្រះរាជក្រឹត្យ


២៨-១១-២០០០ -ព្រះរាជក្រឹត្យនស/រកត/១១០០/២០៣ ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ហ្សង់ អ៊ីទការ្ទី** ១៨២៩

២៨-១១-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៤ តម្លើងឋានៈ និងតែងតាំងឯកឧត្តម **សុក ចមឆានឬទ្ធី** ជាឧបការីសម្តេចក្រុមព្រះប្រធានរដ្ឋសភា ១៨៣០

២៨-១១-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៥ តម្លើងឋានៈ និងតែងតាំងលោកជំទាវ **ញ៉ៀម មរកត** ជាឧបការីសម្តេចក្រុមព្រះប្រធានរដ្ឋសភា ១៨៣០

២៨-១១-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៦ តម្លើងឋានៈ និងតែងតាំងឯកឧត្តម **ហួត ម៉ុងអាន** ជាឧបការីសម្តេចក្រុមព្រះប្រធានរដ្ឋសភា ១៨៣១

២៨-១១-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៧ តែងតាំងឯកឧត្តម **សំ ស៊ីដារិន** ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះប្រធានរដ្ឋសភា ១៨៣២

២៨-១១-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៨ តែងតាំងឯកឧត្តម សំ រសេរី ជាទីប្រឹក្សាសម្តេចក្រុមព្រះប្រធានរដ្ឋសភា ១៨៣៣

២៨-១១-២០០០ - ព្រះរាជក្រឹត្យនស/រកត/១១០០/២០៩ តែងតាំងឯកឧត្តម សុខ ខេម ជាឧបការីសម្តេចក្រុមព្រះប្រធានរដ្ឋសភា ១៨៣៣

២៨-១១-២០០០ - ព្រះរាជក្រឹត្យនស/រកត/១១០០/២១០ តែងតាំងឯកឧត្តម **ឯម ឃិនទរ:** ជាឧបការី សម្តេចក្រុមព្រះប្រធានរដ្ឋសភា ១៨៣៤

២៨-១១-២០០០ - ព្រះរាជក្រឹត្យនស/រកត/១១០០/២១១ តែងតាំងឯកឧត្តម ពុំ សុវណ្ណារិទ្ធិ ជាឧបការី សម្តេចក្រុមព្រះប្រធានរដ្ឋសភា ១៨៣៥

២៨-១១-២០០០ - ព្រះរាជក្រឹត្យនស/រកត/១១០០/២១២ តែងតាំងឧកឧត្តម គែម ឋន ជាអនុរដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ១៨៣៦
២៩-១១-២០០០ - ព្រះរាជក្រឹត្យនស/រកត/១១០០/២១៣ ស្តីពីការបញ្ចូលសមាសភាព ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ១៨៣៦

## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៨-១១-២០០០ - អនុក្រឹត្យ លេខ៨៣ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ១៨៣៨
២៩-១១-២០០០ - អនុក្រឹត្យ លេខ៨៤ អនក្រ.បក ស្តីពីដើមទុនធនាគារជាតិនៃកម្ពុជា ១៨៥៦
៣០-១១-២០០០ - អនុក្រឹត្យ លេខ៨៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៨៥៧
៣០-១១-២០០០ - អនុក្រឹត្យ លេខ៨៦ អនក្រ.បក ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យរបស់ស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស ១៨៤៨
២៩-១១-២០០០ - អនុក្រឹត្យ លេខ៣៨៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៥៣
៣០-១១-២០០០ - អនុក្រឹត្យ លេខ៣៩០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៥៤
៣០-១១-២០០០ - អនុក្រឹត្យ លេខ៣៩១ អនក្រ.តត ស្តីពីការផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ ១៨៥៥
៣០-១១-២០០០ - អនុក្រឹត្យ លេខ៣៩២ អនក្រ.តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ចេញពីក្របខ័ណ្ឌរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ ១៨៥៦
៣០-១១-២០០០ - អនុក្រឹត្យ លេខ៣៩៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៨៥៧
៣០-១១-២០០០ - អនុក្រឹត្យ លេខ៣៩៤ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១៨៥៧
៣០-១១-២០០០ - អនុក្រឹត្យ លេខ៣៩៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៥៩

### ២-សេចក្តីសំរេច

២៨-១១-២០០០ - សេចក្តីសំរេច លេខ ៦៤ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងដើម្បីតាមដាន និងបង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធ ១៨៦០

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១១០០/១១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃ

ទី០៩ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសំរេចថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទប្បញ្ញត្តិ នៃឃ្លាទី១ នៃមាត្រា១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

**ច្បាប់**

**ស្តីពី**

**ច្បាប់បន្ថែមនៅលើច្បាប់ ស្តីពីសវនកម្ម**
**នៃព្រះរាជាណាចក្រកម្ពុជា**

**មាត្រា ១ .-**

ត្រូវបានបំពេញបន្ថែម ជាមាត្រា៥០ ក្នុងជំពូកទី៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០០០ ដូចតទៅ :

**មាត្រា៥០.-** ក្នុងករណីចាំបាច់ តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា រដ្ឋសភាអាចសំរេចបង្កើតគណៈកម្មការពិសេសដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

***

## ២- ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៣

### យើង

### ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
### ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០០

### ត្រាស់បង្គាប់

**មាត្រា ១** .-ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ្សង់ អ៊ីវកាទ្រី** (Jean Yves Catry) សញ្ជាតិដើមបារាំង កើតថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ១៩៥០ នៅ BOURG LA REINE នៃប្រទេសបារាំង ។

**មាត្រា ២** .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៤

យើង

ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/៧៥ ចុះថ្ងៃទី១៩ ខែ មករា ឆ្នាំ ១៩៩៩

-យោងតាមសេចក្ដីក្រាបបង្គំទូលស្នើសុំរបស់សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១៣៥៣ រស ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

មាត្រា ១ .-តម្លើងឋានៈ និងតែងតាំងឯកឧត្តម សុក ចមនានឫទ្ធី ជាឧបការីសម្ដេចក្រុមព្រះប្រធានរដ្ឋសភា ទទួលបន្ទុកទំនាក់ទំនងរាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៥

យើង

ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៥ ចុះថ្ងៃទី១៩ ខែ មករា ឆ្នាំ ១៩៩៩

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១៣៥៣ រស ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

មាត្រា ១ .-តម្លើងឋានៈ និងតែងតាំងលោកជំទាវ ញ៉ែម មរកត ជាឧបការីសម្តេចក្រុមព្រះប្រធានរដ្ឋសភា ទទួលបន្ទុកទំនាក់ទំនងការងារសង្គមកិច្ច មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៦

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៥ ចុះថ្ងៃទី១៩ ខែ មករា ឆ្នាំ ១៩៩៩

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១៣៥៣ រស ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

មាត្រា ១ .-តម្លើងឋានៈ និងតែងតាំងឯកឧត្តម ហួត ម៉ុងអាន ជាឧបការីសម្តេចក្រុមព្រះប្រធានរដ្ឋសភា ទទួលបន្ទុកទំនាក់ទំនងគណបក្សនយោបាយ មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៧

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១០០៩ រស ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

មាត្រា ១ .-តែងតាំងឯកឧត្តម សំ ស៊ីដារិន ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះប្រធានរដ្ឋសភា មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៨

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១០១០ រស ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

មាត្រា ១ .-តែងតាំងឯកឧត្តម សំ សេរី ជាទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រឹត្យ នស/រកត/១១០០/២០៩

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១០០៥ រស ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

**មាត្រា ១** .-តែងតាំងឯកឧត្តម **សុខ ខែម** ជាឧបការីសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១០០/២១០

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១០០៦ រស ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

**មាត្រា ១** .- តែងតាំងឯកឧត្តម **ឯម ឈឹមទរៈ** ជាឧបការីសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ទទួលបន្ទុកសេដ្ឋកិច្ច មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១០០/២១១

### យើង

### ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

### ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជា លេខ ១០០៣ រស ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

### ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម ពុំ សុវណ្ណារិទ្ធិ ជាឧបការីសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

**ព្រះរាជក្រឹត្យ នស/រកត/១១០០/២១២**

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់អនុក្រឹត្យលេខ១៤ អនក្រ ចុះថ្ងៃទី៣០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ .- តែងតាំងឯកឧត្តម កែប ថន ជាអនុរដ្ឋលេខាធិការ នៃក្រសួងសាធារណការនិងដឹកជញ្ជូន ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/១១០០/២១៣**

**ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ**

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

**ត្រាស់បង្គាប់**

មាត្រា ១ .-

ត្រូវបានបញ្ចូលសមាសភាពចំនួនពីរថ្មីទៀត ជាសមាជិកនៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋគឺ :

១-ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍ សង្គមកិច្ច

២-ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

មាត្រា ២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .-

នាយករដ្ឋមន្ត្រី ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវទទួលអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .-

ព្រះរាជក្រឹត្យនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

សមាជិកអចិន្ត្រៃយ៍

ហត្ថលេខា

**សុខ អាន**

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៨៣ អនក្រ.បក

### ស្តីពី

### ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

....

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

### សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំអង្គភាពនានារបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

## ជំពូកទី ២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និង គ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និង អគ្គលេខាធិការរងមួយចំនួន តាមតំរូវការចាំបាច់ ។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានបេសកកម្មដាក់ឱ្យអនុវត្តនូវកម្មវិធីកំណែទំរង់រដ្ឋបាល តាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។ ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋានមានភារកិច្ចជាអាទិ៍ សិក្សា និងលើកសំណើដាក់ជូនរាជរដ្ឋាភិបាល តាមរយៈក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល នូវគំរោងកំណែទំរង់រដ្ឋបាលសំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ជំរុញតាមដានវាយតំលៃលើគំរោងកំណែទំរង់ដែលបានអនុវត្ត ព្រមទាំងរៀបចំធ្វើរបាយការណ៍យ៉ាងទៀងទាត់ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលនៃការអនុវត្តន៍គំរោងទាំងនោះ ។

ក្នុងតួនាទីនេះ អគ្គលេខាធិការបំពេញមុខងារ ទស្សនទាន ផែនការកម្ម ការដាក់ឱ្យដំណើការ ការសំរបសំរួល និងការវាយតំលៃលើគ្រប់គំរោង ដែលមាននៅក្នុងកម្មវិធីកំណែទំរង់រដ្ឋបាល ។ អគ្គលេខាធិការ មានភារកិច្ចពិនិត្យ តាមដាន និងធានាឱ្យមានភាពរលូនក្នុងការអនុវត្តន៍កម្មវិធីកំណែទំរង់រដ្ឋបាល នៅតាមបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរ និងអង្គភាពរដ្ឋ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវធ្វើការប្រជុំការងារ យ៉ាងតិចមួយដងក្នុងមួយខែ តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញការងាររបស់ខ្លួន ។

**មាត្រា ៦.-**

អគ្គលេខាធិការ លើកសំណើជូនប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីពិនិត្យ និងសំរេចលើប្រកាសតែងតាំង តម្លើងឋានៈ ឬ ដកចេញពីតំណែងនូវមន្ត្រី បុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**មាត្រា ៧.-**

អគ្គលេខាធិការរង ជាជំនួយការឱ្យអគ្គលេខាធិការ ។ ការបែងចែកភារកិច្ចរបស់អគ្គលេខាធិការរង ត្រូវកំណត់ដោយប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលតាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានរចនាសម្ព័ន្ធដូចតទៅ :

I- **ក្រុមកិច្ចការដែលស្ថិតក្រោមការដឹកនាំផ្ទាល់របស់អគ្គលេខាធិការ មាន ៥ ក្រុម :**

១- ក្រុមកិច្ចការរដ្ឋបាលទូទៅ

២- ក្រុមកិច្ចការផ្គត់ផ្គង់

៣- ក្រុមកិច្ចការប្រព័ន្ធពត៌មានវិទ្យា

៤- ក្រុមកិច្ចការអភិបាលកិច្ច

៥- ក្រុមកិច្ចការពត៌មាន

II- **អង្គភាពគំរោងសំរាប់អភិវឌ្ឍន៍ និងកែលំអសេវាសាធារណៈ មាន ៤ ក្រុម :**

១- ក្រុមគំរោងវិភាគមុខងារ

២- ក្រុមគំរោងវិសហមជ្ឈការ វិមជ្ឈការ និងសេវាសាធារណៈ

៣- ក្រុមគំរោងនីតិកម្ម

៤- ក្រុមគំរោងកម្មវិធីបណ្តុះបណ្តាល

អង្គភាពនេះ ត្រូវដឹកនាំដោយប្រធានមួយរូបដែលមានឋានៈយ៉ាងទាបស្មើ អគ្គនាយករង ។

III- **អង្គភាពគំរោងគ្រប់គ្រងការផ្លាស់ប្តូរ មាន ៣ ក្រុម :**

១- ក្រុមគំរោងកន្សោមអាទិភាព

២- ក្រុមគំរោងគោលនយោបាយក្របខ័ណ្ឌ និងអធិការកិច្ច

៣- ក្រុមគំរោងប្រព័ន្ធលាភការ

អង្គភាពនេះ ត្រូវដឹកនាំដោយប្រធានមួយរូបដែលមានឋានៈយ៉ាងទាបស្មើ អគ្គនាយករង ។

IV- **អង្គភាពគំរោងសំរាប់គ្រប់គ្រង និងធ្វើសនិទានកម្មមន្ត្រីរាជការ មាន ៣ ក្រុម :**

១- ក្រុមគំរោងជំរឿនមន្ត្រីរាជការ

២- ក្រុមគំរោងសនិទានកម្មមន្ត្រីរាជការ

៣- ក្រុមគំរោងតារាងបៀវត្ស

អង្គភាពនេះ ត្រូវដឹកនាំដោយប្រធានមួយរូបដែលមានឋានៈយ៉ាងទាបស្មើ អគ្គនាយករង ។

**មាត្រា ៩.-**

អគ្គលេខាធិការ លើកសំណើជូនប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីពិនិត្យ និងសំរេចលើការផ្លាស់ប្តូរ ឬ បង្កើតគំរោងផ្សេងៗទៀត តាមតំរូវការចាំបាច់ ។

**មាត្រា ១០.-**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រុមគំរោង និងអង្គភាពនីមួយៗនៃអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**មាត្រា ១១.-**

ក្រុមគំរោងនីមួយៗ មានមុខងារ និងភារកិច្ចចំបងៗដូចតទៅ :

- រ៉ាប់រងអន្តរប្រព័ន្ធបច្ចេកទេស និងទំនាក់ទំនងរវាងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលជាមួយនឹងក្រសួង-ស្ថាប័ននានា
- ផ្តល់យោបល់ និងធ្វើជាជំនួយការបច្ចេកទេសដល់ក្រសួង-ស្ថាប័ននានា
- ធ្វើជាដៃគូពិភាក្សាជាមួយនឹងអ្នកតំណាងរបស់ក្រសួង-ស្ថាប័ននានា លើគំរោងនៃកម្មវិធីកំណែទំរង់រដ្ឋបាល
- រ៉ាប់រងចំពោះអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលលើការអនុវត្តន៍ និងតាមដានការដាក់ឱ្យដំណើការគំរោងកំណែទំរង់នៅក្នុងក្រសួង-ស្ថាប័ននានា ។

**មាត្រា ១២.-**

ក្រុមកិច្ចការរដ្ឋបាលទូទៅ មានមុខងារ និងភារកិច្ចចំបងៗ ដូចតទៅ :

- ជាលេខាធិការដ្ឋានរបស់អគ្គលេខាធិការដ្ឋាន និងជាសេនាធិការផ្ទាល់ឱ្យអគ្គលេខាធិការ ដើម្បីសំរបសំរួលផ្នែករដ្ឋបាលលើរាល់សកម្មភាពក្រុមគំរោង និងអង្គភាពទាំងអស់ក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រង និងចរាចរ លិខិត ឯកសាររដ្ឋបាលផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន
- ធានាប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- បូកសរុប និងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រី បុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ។

**មាត្រា ១៣.-**

ក្រុមកិច្ចការផ្គត់ផ្គង់មានមុខងារ និងភារកិច្ចចំបងៗ ដូចតទៅ :

- ផ្តល់ការផ្គត់ផ្គង់ផ្នែកភស្តុភារ សំភារៈដល់អគ្គលេខាធិការដ្ឋាន
- កសាង និងអនុវត្តគំរោងថវិកា ប្រចាំឆ្នាំ របស់អគ្គលេខាធិការដ្ឋាន
- តាមដាន និងរំលឹកការអនុវត្តន៍ថវិកា និងការគ្រប់គ្រងគណនីរបស់អគ្គលេខាធិការដ្ឋាន
- ប្រមូលចំណូល និងបែងចែកចំណាយរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយឱ្យស្របតាមតំរូវការ និងធ្វើរបាយការណ៍ចំណាយប្រចាំត្រីមាស
- សំរបសំរួល និងតាមដានហិរញ្ញប្បទាន នៃគំរោងកំណែទំរង់តាមផ្នែក របស់ក្រសួងនីមួយៗ ដើម្បីរ៉ាប់រងសហថាមពល នៃធនធាន និងធ្វើឱ្យសំរេចប្រព័ន្ធសេដ្ឋកិច្ចមាត្រដ្ឋាន
- រ៉ាប់រងសេវានៃប័ណ្ណសារ ឯកសារ និងការបកប្រែភាសា ។

**មាត្រា ១៤.-**

ក្រុមកិច្ចការពត៌មាន មានមុខងារ និងភារកិច្ចដូចតទៅ :

- សំរបសំរួលទំនាក់ទំនងជាមួយបណ្តាក្រសួង-ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ និងអង្គភាពរដ្ឋ
- ធ្វើទំនាក់ទំនងល្អជាមួយសាធារណជន អង្គការមិនមែនរដ្ឋាភិបាលក្នុង និងក្រៅប្រទេស អង្គការអន្តរជាតិនានា និងបណ្តាអ្នកតំណាងប្រទេសផ្តល់ជំនួយ
- ប្រមូល និងទុកដាក់ពត៌មាន ឯកសារដែលពាក់ព័ន្ធដល់កម្មវិធីកំណែទំរង់រដ្ឋបាល
- រៀបចំអត្ថបទ និងបោះពុម្ពផ្សាយព្រឹត្តិប័ត្រពត៌មាន និងព្រឹត្តិប័ត្រវេទយិតកម្ម លើកម្មវិធីកំណែទំរង់រដ្ឋបាល ។

**មាត្រា ១៥.-**

ក្រុមកិច្ចការប្រព័ន្ធពត៌មានវិទ្យា មានមុខងារ និងភារកិច្ចចំបងៗ ដូចតទៅ :

- ផ្តល់សេវាប្រព័ន្ធពត៌មានវិទ្យាដល់ក្រុមគំរោង និងក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន
- កសាងមូលដ្ឋានទិន្នន័យ
- បណ្តុះបណ្តាលមន្ត្រីជំនាញកុំព្យូទ័រឱ្យមានឯកទេសគ្រប់គ្រាន់
- បញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធពត៌មានវិទ្យា

- ធានាឱ្យដំណើរការប្រព័ន្ធពត៌មានវិទ្យាឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

**មាត្រា ១៦.-**

ក្រុមកិច្ចការអភិបាលកិច្ច មានមុខងារ និងភារកិច្ចចំបងៗ ដូចតទៅ :

- ផ្តល់យោបល់ និងជាជំនួយការបច្ចេកទេសឱ្យក្រសួង-ស្ថាប័ននានាលើវិស័យអភិបាលកិច្ច
- កសាងសេចក្តីព្រាងនៃផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល
- ធ្វើការសំរបសំរួល និងទំនាក់ទំនងយ៉ាងជិតស្និតជាមួយបណ្តាក្រសួង ក្រុមប្រឹក្សា និងបណ្តាដៃគូសំខាន់ៗដទៃទៀត នៃអភិបាលកិច្ចល្អ
- រ៉ាប់រងចំពោះអគ្គលេខាធិការដ្ឋាន លើការជំរុញតាមដាន និងវាយតំលៃលើការអនុវត្តន៍គំរោងការងារនានា ដើម្បីពង្រឹងអភិបាលកិច្ច នៅតាមក្រសួង-ស្ថាប័ន និងអង្គភាពរដ្ឋ ។

**មាត្រា ១៧.-**

ក្រុមនីមួយៗ ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការ តាមការចាំបាច់ ។ ប្រធានក្រុម មានឋានៈយ៉ាងទាបស្មើ អនុប្រធាននាយកដ្ឋាន ។ អនុប្រធានក្រុមមានឋានៈយ៉ាងទាបស្មើ ប្រធានការិយាល័យ ។

**មាត្រា ១៨.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានសិទ្ធិប្រើប្រាស់មន្ត្រី មុខងារសាធារណៈ និងជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់ ។

មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល អាចទទួលនូវប្រាក់ឧបត្ថម្ភផ្សេងៗ ដែលបានផ្តល់មកពីប្រទេស ឬ អង្គការផ្តល់ជំនួយអន្តរជាតិនានា ។

**ជំពូកទី ៣**

**អវសានប្បញ្ញត្តិ**

**មាត្រា ១៩.-**

អនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវដាក់ជានិរាករណ៍ ។

**មាត្រា ២០.-**

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន និងសមាជិកទាំងអស់ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ហត្ថលេខា និងត្រា

**សុខ អាន**

# រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល



# អនុក្រឹត្យ លេខ ៨៤ អនក្រ.បក
## ស្តីពី ដើមទុនធនាគារជាតិនៃកម្ពុជា

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

-តាមសំណើរទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សម្រេច

មាត្រា ១ .- កំណត់ដើមទុនរបស់ធនាគារជាតិនៃកម្ពុជា ចំនួន ១០០.០០០.០០០.០០០.០០រៀល (មួយរយពាន់លានរៀល) ។

មាត្រា ២ .-

ធនាគារជាតិនៃកម្ពុជា ត្រូវចាត់ចែងការចុះបញ្ជីកា ក្នុងតារាងតុល្យការរបស់ខ្លួនអោយបានគ្រប់ចំនួន ។

មាត្រា ៣ .-

ដើមទុនខាងលើនេះត្រូវបានចុះបញ្ជី និងកាន់កាប់ផ្តាច់មុខដោយរាជរដ្ឋាភិបាល និងមិនអាចផ្ទេរ ឬដាក់អោយជាប់ល័ក្ខខ័ណ្ឌអ្វីឡើយ ។

មាត្រា ៤ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០២ ខែ តុលា ឆ្នាំ ២០០០

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា
ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

ទេសាភិបាលធនាគារជាតិនៃកម្ពុជា
ហត្ថលេខា
**ជា ចាន់តូ**

# អនុក្រឹត្យ លេខ ៨៥ អនក្រ.បក
## ស្តីពី ការផ្ទេរឥណទានថវិកាជាតិ

* * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១នស/៩៣ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០០

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១៩៩.៥០០.០០០រៀល (មួយរយកៅសិបប្រាំបួនលានប្រាំរយពាន់រៀល) ពីជំពូក៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា ) មកជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០០ ។

**មាត្រា ២.-** ឥណទានថវិកាក្នុងមាត្រា១ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្តេចព្រះរាមរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

**ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ៨៦ អនក្រ.បក

## ស្ដីពី

## ការគ្រប់គ្រងថវិកា និងគណនេយ្យរបស់ស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង-ខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្ដីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ៣០ បប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សំរេច
## ជំពូកទី ១
## បទប្បញ្ញត្តិ
## ស្តីពី
## ប្រធានស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស ជាអាណាប័កផ្ទេរសិទ្ធិចំណាយ

មាត្រា ១ .- ចំណាយនានានៃស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវស្ថិតនៅក្រោមវិធាន ដែលបានបញ្ញត្តិដោយអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទ បញ្ញាទូទៅ នៃគណនេយ្យសាធារណៈដែលបានចែងក្នុងភាគ III ជំពូកទី២ ចាប់ពីមាត្រា៤៥ ដល់ មាត្រា៦៧ លើក លែងបដិប្បញ្ញត្តិដែលប្រកាសអោយប្រើដោយមានមាត្រា២.៣.៤.និង៥ ដូចខាង ក្រោមនេះ :

មាត្រា ២.- ឯកអគ្គរាជទូត អគ្គកុងស៊ុល ភារៈធារី ដែលជាប្រធានបេសកកម្មទូត ហើយមានតួនាទី ជាប្រធាន ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវមានមុខងារជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រី ក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើចំណាយទាំងឡាយនៃស្ថានតំណាងដែល ខ្លួនដឹកនាំ ។ ជារៀងរាល់ឆ្នាំ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាអា ណាប័កដើមខ្សែ ត្រូវផ្ទេរឥណទានជូនស្ថានតំណាងទាំងនោះនៅបរទេស ដែលត្រូវទទួលហើយ ដែលបានចុះបញ្ជីកានៅក្នុង ថវិកា នៃក្រសួងសាមី ។

មាត្រា ៣ .- នៅដើមត្រីមាសនីមួយៗ គ្រប់ស្ថានតំណាងនៅបរទេសត្រូវផ្តល់តាមរយៈអាណត្តិបើកប្រាក់រួមលើ ថវិការបស់ក្រសួង នូវទាយជ្ជទានរួមមួយស្មើនឹងមួយភាគបួន នៃឥណទានប្រចាំឆ្នាំដែលត្រូវផ្តល់អោយ ស្ថានតំណាងទាំងនោះ ។ តាមរយៈអាណត្តិបើកប្រាក់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្វែរ ចំនួនប្រាក់ ដែលបានផ្តល់ចូលគណនីចរន្តរបស់ស្ថានតំណាងទាំងនោះ ដែលបានបើកនៅធនាគារ ។

មាត្រា ៤ .- ប្រធានស្ថានតំណាងនៅបរទេសត្រូវចាត់នីតិវិធី ក្រោមការទទួលខុសត្រូវ ធ្វើការសន្យា និងជំរះបញ្ជី ចំណាយ នៃស្ថានតំណាងរបស់ខ្លួននៅក្នុងក៏រិតនៃឥណទានដែលបានបែងចែកជូន និងមូលនិធិដែល បានទទួល ។

មាត្រា ៥ .- ដោយបដិប្បញ្ញត្តិចំពោះបទប្បញ្ញត្តិនានា ដែលបានចែងក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាម ក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ការសន្យាចំណាយនានារបស់ ស្ថានតំណាងនៅបរទេស មិនស្ថិតនៅក្រោមការអនុញ្ញាតមតិយោបល់ ឬទិដ្ឋាការណាមួយឡើយ ។

# ជំពូកទី ២

## បទប្បញ្ញត្តិ

## ស្ដីពី ភ្នាក់ងារគណនេយ្យនៃស្ថានតំណាង

## នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

មាត្រា ៦ .- នៅអមស្ថានតំណាងកម្ពុជានីមួយៗនៅបរទេស ត្រូវមានភ្នាក់ងារគណនេយ្យម្នាក់ ដែលត្រូវបានតែងតាំងដោយប្រកាសអន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៧ .- ភ្នាក់ងារគណនេយ្យមានតួនាទី ជាគណនេយ្យករដោយឡែក ។ តាមរយៈតួនាទីនេះ ការគ្រប់គ្រងរបស់ខ្លួន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបានវិនិច្ឆ័យផងដែរពីអាជ្ញាធរសវនកម្មជាតិ ។

មាត្រា ៨ .- ភ្នាក់ងារគណនេយ្យត្រូវចុះទិដ្ឋាការ និងទូទាត់ចំណាយទាំងឡាយណាដែលប្រធានស្ថានតំណាង នៅបរទេសបានសន្យា និងបានជំរះត្រឹមត្រូវរួចហើយ ។ ការទូទាត់ចំណាយទាំងនេះប្រព្រឹត្តិទៅដោយគ្មានអាណត្តិកិច្ចទេ តែត្រូវអនុលោមតាមវិធានដែលបានបញ្ញត្តិ សំរាប់ការទូទាត់ចំណាយរបស់រដ្ឋ តាមមាត្រាពី៥៧ ដល់មាត្រា៦៣នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ លើកលែងតែបទប្បញ្ញត្តិដោយឡែកដូចខាងក្រោមនេះ :

ក/ ការផ្គត់ផ្គង់សំភារៈ ការងារសាងសង់ និងសេវាកម្ម ត្រូវបានទូទាត់ដោយផ្អែកតាមលិខិតយុត្តការណ៍ស្របច្បាប់ ។

ខ/ ប្រសិនបើការទូទាត់ធ្វើដោយមូលប្បទានប័ត្រ មូលប្បទានប័ត្រនោះត្រូវបរិយាយអោយបានច្បាស់លាស់ អំពីឥណទាយកពិតប្រាកដ និងយោងមូលប្បទានប័ត្រនេះ ទៅក្នុងវិក្កយបត្រ ឬសារណាដែលមាន ។ អាចយកជាការបាននូវការរំដោះបន្ទុកនៃភាគីដែលទទួល ចំពោះមូលប្បទានប័ត្រ ដែលធនាគារបានទូទាត់ហើយ ឬ បន្ទាប់ពីមានការបញ្ជាក់នៃការទូទាត់លើសម្រង់សរុបរបស់ធនាគារ ។

គ/ មូលនិធិនៃស្ថានតំណាងនៅបរទេស ត្រូវតំកល់ជាដាច់ខាត នៅក្នុងគ្រឹះស្ថានធនាគារណាមួយដែលត្រូវបានអនុញ្ញាតដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៩ .- ម្យ៉ាងទៀត ភ្នាក់ងារគណនេយ្យ នៃស្ថានតំណាងនៅបរទេស ត្រូវទទួលបន្ទុកប្រមូលចំណូលរបស់ស្ថានតំណាង ដែលខ្លួនទទួលរ៉ាប់រង ។ ទន្ទឹមនេះត្រូវធ្វើរបាយការណ៍ពីស្ថានភាពចំណូលជាក់ស្ដែងនោះមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈសាមីក្រសួង នៅរៀងរាល់ខែនីមួយៗ ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមូលដ្ឋានផ្ដល់ជូនបំពេញបន្ថែមនូវថវិកាត្រូវចំណាយសំរាប់ត្រីមាសនីមួយៗ ។ ភ្នាក់ងារ

គណនេយ្យត្រូវទទួលថែរក្សានិងចុះបញ្ជីកា ទ្រព្យសម្ភារឹមនានា ដែលបានផ្តល់អោយស្ថានតំណាងទាំងនោះអោយបានត្រឹមត្រូវ ។

មាត្រា១០.- មានតែភ្នាក់ងារគណនេយ្យ និងអ្នកផ្ទេរសិទ្ធិរបស់ខ្លួនទេ ដែលអាចកាន់កាប់មូលនិធិសាធារណៈនេះ ។

មាត្រា១១ .- អនុលោមទៅនឹងបទប្បញ្ញត្តិនានា នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ភ្នាក់ងារគណនេយ្យត្រូវទទួលខុសត្រូវ ផ្ទាល់ខ្លួន និងជាប្រាក់កាស នូវកិច្ចប្រតិបត្តិការដែលខ្លួនទទួលបន្ទុក(បទប្បញ្ញត្តិទាំងឡាយនៃមាត្រា១២ និងមាត្រា ១៦) និងកិច្ចការត្រួតពិនិត្យជាទៀងទាត់ដែលខ្លួនត្រូវរ៉ាប់រង (បទប្បញ្ញត្តិនៃមាត្រា១៣) ព្រមទាំងការពារថែរក្សាទុកដាក់ប្រាក់កាស តម្លៃផលិតផល និងវត្ថុធាតុផ្សេងៗដែល បានប្រគល់អោយកាន់កាប់ (បទប្បញ្ញត្តិនៃមាត្រា១០២) ។ ការទទួលខុសត្រូវជាប្រាក់កាសនៃភ្នាក់ងារ គណនេយ្យនេះ មានរហូតដល់មន្ត្រីទាំងឡាយដែលប្រតិបត្តិការ នៅក្រោមបង្គាប់របស់ ភ្នាក់ងារ គណនេយ្យផងដែរ ។

មាត្រា ១២ .- កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃស្ថានតំណាងនៅបរទេស ត្រូវបានចុះបញ្ជីកាគណនេយ្យ តាមទម្រង់បែបបទ ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៣

## បទប្បញ្ញត្តិ

## ស្តីពី

## កិច្ចបញ្ជីកា គណនេយ្យ

## នៃស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

មាត្រា ១៣ .- ភ្នាក់ងារគណនេយ្យនៃស្ថានតំណាងនៅបរទេស ក្នុងតួនាទីខ្លួនជាគណនេយ្យករសាធារណៈ ត្រូវផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នូវឯកសារគណនេយ្យដូចតទៅ :

ក/ ជីកាស្តីពីកិច្ចប្រតិបត្តិការចំណូល និងចំណាយក្នុង និងក្រៅថវិកា និងកិច្ចប្រតិបត្តិការរតនៈវត្ថុមួយច្បាប់ ដែលបានអនុវត្តនៅក្នុងខែកន្លងទៅ ដោយភ្ជាប់ជាមួយនូវលិខិតយុត្តិការណ៍ នៃចំណូល និងចំណាយ ។

ខ/ នៅដំណាច់ឆ្នាំ គណនីគ្រប់គ្រងប្រចាំឆ្នាំ និងតារាងស្ថានភាព នៃបញ្ជីចំណូលដែលបានបោះផ្សាយចំណូលដែលប្រមូលបាននិងចំណូលដែលនៅសល់ដែលត្រូវប្រមូលតទៅទៀត ។ គណនីគ្រប់គ្រងប្រចាំឆ្នាំនេះត្រូវបានបង្ហាញនូវ :

-ស្ថានភាពគណនេយ្យនៅថ្ងៃទី០១ ខែ មករា នៃឆ្នាំ (សមតុល្យដើមឆ្នាំ)

-អធិប្បាយអំពីកិច្ចប្រតិបត្តិការចំណូល និងចំណាយគ្រប់ប្រភេទដែលបានអនុវត្តនៅក្នុងឆ្នាំធ្វើការវិភាគអោយច្បាស់លាស់ រវាងកិច្ចប្រតិបត្តិការថវិកា និងកិច្ចប្រតិបត្តិការក្រៅថវិកា ឬកិច្ចប្រតិបត្តិការរតនៈវត្ថុ ។

-ស្ថានភាពគណនេយ្យនៅថ្ងៃទី៣១ ខែ ធ្នូ នៃឆ្នាំ (សមតុល្យចុងឆ្នាំ)

គ/ គណនីប្រចាំឆ្នាំ ត្រូវផ្អែកទៅនឹងបញ្ជីសារពើភ័ណ្ឌទូទៅមួយ ព្រមទាំងបូកសរុបលិខិតយុត្តការណ៍នានាស្តីពីចំណាយដែលបានទូទាត់នៅក្នុងឆ្នាំ និងបានកសាងឡើង ផ្អែកតាមកិច្ចបញ្ជិកាប្រចាំខែ។

ឃ/ ឯកសារទាំងអស់ត្រូវផ្តល់តាមពេលវេលាដែលបានកំណត់ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៤ .-** លេខនា និងសៀវភៅបញ្ជីគណនេយ្យរបស់ភ្នាក់ងារគណនេយ្យ នៃប្រាក់កាសសាធារណៈ ត្រូវបញ្ឈប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ។

**មាត្រា ១៥ .-** ស្ថានភាពបេឡា និងតម្លៃផ្សេងៗត្រូវបានរៀបចំនៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ និងត្រូវបានបញ្ជូនដោយភ្នាក់ងារគណនេយ្យ ដោយផ្អែកទៅនឹងគណនីប្រចាំឆ្នាំរបស់ខ្លួន ។

**មាត្រា ១៦ .-** ភ្នាក់ងារគណនេយ្យ នៃស្ថានតំណាងនៅបរទេស ត្រូវកាន់កាប់នូវគណនេយ្យរូបធាតុ សំរាប់ទ្រព្យសង្ហារិមនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៧ .-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែល មានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួនក្នុងការអនុវត្តន៏អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
ហត្ថលេខា
**ហោ ណាំហុង**

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ៣៨៩ អនក្រ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ១៤/អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ៨១/អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

មាត្រា ១ .- ត្រូវបានតែងតាំងលោក រស់ ទណ្ណា ជាអគ្គនាយកសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) នៃក្រសួងសាធារណការនិងដឹកជញ្ជូន ជំនួសលោក កែម ថន ដែលត្រូវទៅទទួលភារកិច្ចថ្មី ។

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ៣៩០ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងលោក **ផែន ម៉ុនទ័ាត់** អភិបាលរងស្រុកបានលុង ជាអភិបាលស្រុកវឺនសៃ ខេត្តរតនគិរី ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យ លេខ ៣៩១ អនក្រ.

## ស្តីពី

## ការផ្លាស់ប្តូរភារកិច្ចរបស់មន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-** ត្រូវបានផ្លាស់លោក **ហេង ម៉ុនចាន់** អភិបាលស្រុកវើនសៃ អោយមកទទួលមុខតំណែងថ្មី ជាអភិបាលស្រុក អូរយ៉ាដាវ ខេត្តរតនគិរី ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យ លេខ ៣៩២ អនក្រ.តត
# ស្តីពី
# ការលុបឈ្មោះមន្ត្រីរាជការ
# ចេញពីក្របខ័ណ្ឌរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-** ត្រូវបានលុបឈ្មោះលោក សល់ សាន ចេញពីក្របខ័ណ្ឌរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ ដោយមូលហេតុទទួលមរណភាព ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៣៩៣ អនក្រ.តត
## ស្តីពី
## ការជូនមេដាយសហមេត្រី

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយ អស្សឫទ្ធិ សហមេត្រី ជូនលោក LAI KIM TENG ប្រធានក្រុមហ៊ុនម៉ាឡេស៊ី ដែលមានគុណបំណាច់ ក្នុងការចូលរួមតម្លើងរោងចក្រកែច្នៃកៅស៊ូក្រេប និងការងារដាំដុះកូនកៅស៊ូ នៅចំការកៅស៊ូពាមជាំង ខេត្តកំពង់ចាម ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៣៩៤ អនក្រ.តត
## ស្តីពី
## ការជូនមេដាយ សុវត្ថារា

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ជូនមន្ត្រីដឹកនាំ និងអ្នកបច្ចេកទេស ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការតម្លើងរោងចក្រកែច្នៃជ័រកៅស៊ូក្រេប និងការងារដាំដុះកូនកៅស៊ូ នៅចំការកៅស៊ូពាមជាំង ដូចមានរាយនាមខាងក្រោមនេះ ៖

ក/ធិបឌិន្ទ សុវត្ថារា ៖

| | | |
|---|---|---|
| ១-ឯកឧត្តម | លី ផល្លា | អគ្គនាយកនៃអគ្គនាយកដ្ឋានចំការកៅស៊ូ |
| ២-លោក | ម៉ែន ស៊ីផាន់ | ប្រធានអគ្គនាយកចំការកៅស៊ូ ពាមជាំង |

ខ/សេនា សុវត្ថារា ៖

| | | |
|---|---|---|
| ១-លោក | ស្វាយ វឌ្ឍនា | អនុប្រធាននាយកដ្ឋានផែនការគណនេយ្យ |
| ២-លោក | អ៊ូន សុវណ្ណ | នាយកទទួលបន្ទុកបច្ចេក |
| ៣-លោក | ព្រុំ ឈុនឡេង | អនុប្រធានការិយាល័យប. |
| ៤-លោក | ឆួច ឧត្តី | វិស្វករអគ្គិសនី |
| ៥-លោក | ហែម សម្បត្តិ | មន្ត្រីទទួលបន្ទុកដាំដុះ |
| ៦-លោក | ពិន មុនីរ៉ា | ប្រធានភូមិ៤៩ |
| ៧-លោក | ឈឹម ធីរិទ្ធិ | ប្រធានកសិដ្ឋាន |

គ/អស្សឫទ្ធិ សុវត្ថារា ៖

| | | |
|---|---|---|
| ១-លោក | ម៉ែន ធី | ជាងតម្លើងម៉ាស៊ីន |
| ២-លោក | ដួង រតនា | វិស្វករដាំដុះ . |
| ៣-លោក | ហេង សុគន្ធា | ប្រធានការិយាល័យបច្ចេកទេស |
| ៤-លោក | ថ្វី ពៅ | មន្ត្រីគមនាគមន៏ |

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៣៩៥ អនក្រ.តត

### ស្តីពី

### ការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់ របស់រាជរដ្ឋាភិបាល

### សំរេច

មាត្រា ១ .- ត្រូវបានតម្លើងឋានៈអស់លោកសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ដូចមានរាយនាមខាងក្រោម

១-លោក ឯក ធីរៈជេដ្ឋ

២-លោក ម៉ុញ្ញ បានកុសល

៣-លោក ឈឹម សាអែត

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## ២- សេចក្តីសំរេច

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៦៤ សសរ

### ស្តីពី

### ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីតាមដាន និង បង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/០២/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសភាពការណ៍ចាំបាច់ របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ .- បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីតាមដាន និងបង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ស ខេង | ឧបនាយករដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម យូ ហុកគ្រី | សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម ទៀ បាញ់ | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៤-ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ស៊ីរីរ័ត្ន | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | កែ គឹមយ៉ាន | អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦-ឯកឧត្តម | ហុក ឡុងឌី | អគ្គនាយកនគរបាលជាតិ | សមាជិក |
| ៧-ឯកឧត្តម | ខិម យ៉ិនឡៅង | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៨-ឯកឧត្តម | អង្គ វង្សវឌ្ឍានា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៩-ឯកឧត្តម | ពេជ្រ ម៉ុនធិន | រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ១០-ឯកឧត្តម | ឡុង វិសាលោ | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១-ឯកឧត្តម ឧត្តមសេនីយ៍ឯក | មាស សុផា | អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ | សមាជិក |
| ១២-ឯកឧត្តម ឧត្តមសេនីយ៍ឯក | មល់ រឿម | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ១៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក | សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ | យូ ស៊ិនឡុង | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ១៥-ឯកឧត្តម ឧត្តមសេនីយ៍ទោ | នេត្រ សាវឿន | ប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦-ឯកឧត្តម | ណាំ នុំ | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី | សមាជិក |
| ១៧-លោកឧត្តមសេនីយ៍ត្រី | ជុំ ហាក់ | ប្រធានការិយាល័យទី២ កងទ័ពជើងគោក | សមាជិក |
| ១៨-លោកឧត្តមសេនីយ៍ត្រី | សុខ ផល | ប្រធាននាយកដ្ឋានព័ត៌មានទូទៅក្រសួងមហាផ្ទៃ | សមាជិក |
| ១៩-លោកឧត្តមសេនីយ៍ត្រី | គន្ធ សំអឿន | ប្រធាននាយកដ្ឋានភេរវកម្មក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ២ :** គណៈកម្មការចំរុះអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

-ស្រាវជ្រាវត្រួតពិនិត្យ និងតាមដានអោយបានច្បាស់លាស់នូវរាល់សកម្មភាពភេរវកម្មប្រដាប់អាវុធ ដែលបង្កឡើងដោយក្រុមជនមួយចំនួន ដើម្បីបំផ្លិចបំផ្លាញសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខ សុវត្ថិភាពសង្គម ។

-លើកវិធានការទប់ស្កាត់ និងបង្ក្រាបអោយមានប្រសិទ្ធភាពតាមផ្លូវច្បាប់ ។

-លើកសំណើជូនរាជរដ្ឋាភិបាលសុំផ្អាកការងារបណ្តោះអាសន្ន មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈយោធិន កងរាជអាវុធហត្ថ និងនគរបាល ដែលពិនិត្យឃើញមានការពាក់ព័ន្ធជាមួយ

នឹងអំពើភេរវកម្មប្រដាប់អាវុធ ដើម្បីងាយស្រួលក្នុងការធ្វើការស្រាវជ្រាវ និងចាត់ការបន្តតាមនីតិច្បាប់ ។

-ធ្វើសហប្រតិបត្តិការចរចា និងសំរបសំរួលជាមួយបណ្តាប្រទេស ដែលពួកភេរវកម្មប្រដាប់អាវុធបាននឹងកំពុងស្នាក់នៅ ដើម្បីចាត់បញ្ជូនតាមផ្លូវច្បាប់ប្រគល់មកអោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាដោះស្រាយ ឬចាត់ការកាត់ទោសតាមផ្លូវច្បាប់ នៃប្រទេសដែលពោលខាងលើ ។

-ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលអនុវត្ត និងសុំយោបល់សំរេចក្នុងករណីចាំបាច់ ។

**ប្រការ ៣ :** គណៈកម្មការចំរុះអន្តរក្រសួង មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយតាមការចាំបាច់ ដើម្បីជាជំនួយការ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★